# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាថ្ងៃសុក្រពិសិដ្ឋ
# ភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩
# ខ្ញុំជាសេចក្ដីពិត

**អត្ថបទទី១៖ អេសាយ ៥២,១៣-៥៣,១២**

តាមពិត លោកបានរងទុក្ខវេទនាជំនួសយើង លោកទទួលយកការឈឺចាប់របស់យើង មកដាក់លើខ្លួនលោក។ អស ៣,៤

**អត្ថបទទី២៖ ហេប្រឺ ៤,១៤-១៦.៥,៧-៩**

ថ្វីដ្បិតតែព្រះអង្គជាព្រះបុត្រាក៏ដោយ ព្រះអង្គក៏បានរៀនស្ដាប់បង្គាប់ ដោយរងទុក្ខលំបាក។ ហាប ៥,៨

**ដំណឹងល្អ៖ យ៉ូហាន ១៨,១-១៩,៤២**

ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «គឺខ្ញុំហ្នឹងហើយ»។ ។ យហ ១៨,៥

បងប្អូនជាទីស្រឡាញ់!

ព្រះយេស៊ូបានសោយទិវង្គតហើយ សូមបងប្អូននៅស្ងៀមស្ងាត់ដោយអធិដ្ឋាននៅក្នុងដួងចិត្តរបស់យើង ដោយទទួលព្រះបន្ទូលដែលយើងបានស្ដាប់។ យប់មិញ យើងបានអង្គុយរួមគ្នាជាមួយព្រះយេស៊ូដែលបានជប់លៀងជាមួយក្រុមសាវ័ក និងជាមួយយើងដែរ ហើយព្រះអង្គមានព្រះបន្ទូលថា "**នេះជាព្រះកាយ នេះជាព្រះលោហិតរបស់ខ្ញុំ**"។ ថ្ងៃនេះ យើងឃើញជាក់ស្ដែង ព្រះកាយរបស់ព្រះគ្រីស្តនៅលើឈើឆ្កាង ព្រះលោហិតរបស់ព្រះគ្រីស្តបានហូរចេញពីទ្រូងរបស់ព្រះអង្គ។ ព្រះបន្ទូលរបស់ព្រះយេស៊ូបានចេញជារូបរាងហើយ ព្រះយេស៊ូបានសោយទិវង្គតក្នុងអត្ថន័យថាព្រះយេស៊ូបានបូជាជីវិត ដើម្បីឲ្យយើងទទួលជីវិត ដើម្បីឲ្យយើងទទួលពន្លឺនៅក្នុងដួងចិត្តរបស់យើង។ យើងបានស្ដាប់ហើយ លោក ពីឡាត់ រកមិនឃើញមូលហេតុដើម្បីស្លាប់ព្រះយេស៊ូ លោក ពីឡាត់ រកមិនឃើញមូលហេតុដែលគេចង់ឆ្កាងព្រះយេស៊ូដូចនេះ មូលហេតុដែលគេស្អប់ព្រះយេស៊ូដល់កម្រិតនេះ។ លោក ពីឡាត់ រកមិនឃើញមូលហេតុ ប៉ុន្តែគេចង់ឲ្យព្រះយេស៊ូស្លាប់ លោក ពីឡាត់ បានស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូថា "**ខ្ញុំជាសេចក្ដីពិត**"។ ព្រះយេស៊ូជាសេចក្ដីពិត ដោយសារព្រះអង្គពោរពេញដោយភាពដ៏វិសុទ្ធ ព្រះយេស៊ូជាព្រះអម្ចាស់ដ៏សុចរិត ធ្វើដូចម្ដេចដើម្បីឆ្កាងព្រះយេស៊ូដូចមនុស្សទុច្ចរិត ដូចអ្នកបាប ដូចមនុស្សដែលប្រព្រឹត្តអំពើឃោរឃៅ។

ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំមិនមែនមកពីលោកីយនេះទេ គឺព្រះជាម្ចាស់ដែលជាព្រះបិតាបានចាត់ខ្ញុំឲ្យមក**" នៅពេលនេះរួមជាមួយប្រជាជនយើងនឹកឃើញគ្រប់ស្នាព្រះហស្តរបស់ព្រះអង្គដូចជា ព្យាបាលអ្នកជំងឺឲ្យជាសះស្បើយ ណែនាំអ្នកដែលអស់សង្ឃឹមរកឃើញពន្លឺ

នៅក្នុងជីវិត ណែនាំឲ្យមនុស្សបាបមានជីវិតថ្មី... ព្រះយេស៊ូបានណែនាំឲ្យមនុស្សជាច្រើនរកឃើញសេចក្ដីសង្ឃឹមសារជាថ្មី។ ថ្ងៃនេះ ដែលគេឆ្កាងព្រះយេស៊ូយើងដឹងថា ទុក្ខលំបាករបស់យើងផ្ទាល់ ទុក្ខលំបាករបស់មនុស្សលោក ទុក្ខលំបាករបស់ព្រះសហគមន៍យើងអាចផ្ញើទៅលើព្រះយេស៊ូ។ គ្រប់ពេលវេលាដែលយើងមើលឃើញ ភាពអយុត្តិធម៌ ការស្អប់គ្នា សង្គ្រាម ការសម្លាប់ទាំងវិញ្ញាណ ទាំងផ្លូវចិត្ត ទាំងរូបកាយ...។ គ្រប់ពេលវេលានោះ យើងស្ដាប់ម្ដងទៀតព្រះយេស៊ូដែលមានព្រះបន្ទូលថា "**ខ្ញុំស្រេកទឹក**" **តើយើងជាអ្នកដែលឲ្យទឹកទៅព្រះយេស៊ូឬ? តើយើងជាអ្នកដែលណែនាំឲ្យមនុស្សតូចតាចរកឃើញផ្លូវនៅក្នុងជីវិតឬ?** កុមារកំព្រា ស្ដ្រីមេម៉ាយ គ្រួសារដែលគ្មានសេចក្ដីសុខ **តើយើងធ្វើដូចម្ដេចដើម្បីឲ្យមនុស្សទាំងអស់ចូលនៅក្នុងគ្រួសាររបស់ព្រះគ្រីស្ដ ដើម្បីរកឃើញសេចក្ដីសង្ឃឹមនៅក្នុងជីវិត?** ជាពិសេស កូនក្មេងដែលគេប្រើធ្វើជាទាសករ កូនក្មេងដែលបាត់ភាពវិសុទ្ធដោយសារមនុស្សពង្វក់ឲ្យវង្វេងផ្លូវ កូនក្មេងដែលបាត់បង់ជីវិតដោយសារសង្គ្រាមឬបញ្ហាផ្សេងៗ កូនក្មេងដែលគ្មានវាសនាទទួលការអប់រំ ទទួលសេវាសុខភាព មានទីលំនៅសមរម្យ មានឪពុកម្ដាយដែលស្រឡាញ់និងមើលថែទាំដូចគេ យើងថ្វាយទៅព្រះជាម្ចាស់។ យើងស្ដាប់ព្រះយេស៊ូដែលមានព្រះបន្ទូលថា "**ខ្ញុំស្រេកទឹក**" ឲ្យយើងយល់ថានេះជាតួនាទីរបស់យើងដែលជាសាវ័ករបស់ព្រះគ្រីស្ដ ដែលអង្គុយនៅក្បែរឈើឆ្កាងនៅពេលនេះ ដើម្បីបន្តបេសកកម្មដែលព្រះយេស៊ូបានចាប់ផ្ដើមបន្តប្រកាសដំណឹងល្អ។ ប៉ុន្តែ មិនមែនបន្តប្រកាសដំណឹងល្អដោយមានពាក្យនិយាយយ៉ាងច្រើន ប្រកាសដំណឹងល្អដើម្បីឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូទៅជារូបរាងនៅពេលនេះ នៅទីនេះ នៅក្នុងព្រះសហគមន៍យើង នៅក្នុងប្រទេសកម្ពុជាយើង នៅក្នុងគ្រួសារយើង។

ដូច្នេះយើងនៅស្ងៀមស្ងាត់ សម្លឹងមើលព្រះឈើឆ្កាងដោយនឹកឃើញទុក្ខលំបាកនៅក្នុងគ្រួសារយើង ទុក្ខលំបាកនៅក្នុងជីវិតយើង ទុក្ខលំបាកនៅក្នុងព្រះសហគមន៍យើង ទុក្ខលំបាកនៅក្នុងសង្គមយើង ដោយផ្ញើទុក្ខលំបាកនេះទាំងអស់ទៅលើព្រះយេស៊ូ ដោយទូលអង្វរព្រះអង្គថា "**ឱព្រះអម្ចាស់អើយ! សូមអាណិតមេត្តាយើងខ្ញុំផង! ឱព្រះអម្ចាស់អើយ! សូមអាណិតមេត្តាយើងខ្ញុំផង! ឱព្រះអម្ចាស់អើយ! សូមអាណិតមេត្តាយើងខ្ញុំផង!**"។ អាម៉ែន៕